**BBI0096**

# សម្ភាសជាមួយឈ្មោះ សយ ឈួន ភេទ ស្រី អាយុ ៥១ឆ្នាំ

មុខងារខ្មែរក្រហមៈ នារីដឹកជញ្ជូន

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

មានស្រុកកំណើតនៅៈ ភូមិជង្រុក ឃុំតាឡូង ស្រុកបាកាន ខេត្តពោធិ៍សាត់

សព្វថ្ងៃរស់នៅភូមិពេជ្រចិន្តា ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០០:២០:២២

១៣ទំព័រ

សេងគា ៖ បាទ! ថ្ងៃនេះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១ ។ បាទ! ខ្ញុំឈ្មោះសេងគា ខ្ញុំមកពីមជ្ឈមណ្ឌលកម្ពុជា ហើយម៉ោនេះចង់ជួបមីងដើម្បីយកបទសម្ភាសន៍ ដូចខ្ញុំបានប្រាប់មីងមិញអញ្ចឹង ដើម្បីយកចងក្រងជាឯកសារសម្រាប់ទុកឲ្យក្មេងយកទៅសិក្សារៀនសូត្រ និងប្រើប្រាស់ផ្សេងៗទៀត អញ្ចឹងមីងក៏អនុញ្ញាតឲ្យខ្ញុំយកទៅប្រើប្រាស់ដែរមីង អញ្ចឹងខ្ញុំក៏ចង់ស្គាល់ឈ្មោះមីងដែរមីងឈ្មោះអីមីង?

ឈួន ៖ សយ ឈួន ។

សេងគា ៖ សយ ឈួន មីងអាយុប៉ុន្មានហើយ?

ឈួន ៖ ៥១ឆ្នាំ ។

សេងគា ៖ ៥១ឆ្នាំ ស្រុកកំណើតមីងឈ្មោះអីដែរមីង?

ឈួន ៖ ស្រុកកំណើតខ្ញុំនៅភូមិជង្រុក ឃុំតាឡូង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

សេងគា ៖ មីងកើតនៅឆ្នាំ ១៩៥៩មីង?

ឈួន ៖ ឆ្នាំ១៩៥៩ ។

សេងគា ៖ ឪពុកមីងស្លាប់នៅឆ្នាំ?

ឈួន ៖ ឆ្នាំ៦០ ។

សេងគា ៖ គាត់ឈ្មោះអីគេមីង?

ឈួន ៖ ឈ្មោះ សយ ។

សេង៍គា ៖ ឈ្មោះ សយ អត់ចាំត្រកូលទេ ម្ដាយឈ្មោះ?

ឈ្មួន ៖ ឈ្មោះ ឈឿន ។

សេង៍គា ៖ ឈ្មោះ ឈឿន ក៏អត់ចាំត្រកូលដូចគ្នា?

ឈ្មួន ៖ ចាំ!

សេង៍គា ៖ អញ្ចឹងនៅឆ្នាំ១៩៧០ មីងមានអាយុប៉ុន្មាន?

ឈ្មួន ៖ អាយុ១៨ឆ្នាំ ។

សេង៍គា ៖ ១៨ឆ្នាំ អញ្ចឹងមីងក៏បាន ដោយសារមានសម័យលន់ ណុល មីងក៏បាន មីងអាចរៀបរាប់កន្លែងហ្នឹងបន្តិចបានទេ?

ឈ្មួន ៖ នៅសម័យលន់ ណុល នៅឆ្នាំ៧០ ហ្នឹងខ្ញុំបានរៀននៅក្នុងភូមិរបស់ខ្ញុំហ្នឹងរៀនបានត្រឹមថ្នាក់ទី៤ រៀនពីថ្នាក់ទី១ ទៅដល់ថ្នាក់ទី៤រាប់ពី១ ឡើងទៅ ។

សេង៍គា ៖ បាទ!រាប់ពី១ ឡើងទៅ កាលហ្នឹងមានគ្រូឈ្មោះអីខ្លះ?

ឈ្មួន ៖ គ្រូឈ្មោះ ថ្នាក់ទី១ ឈ្មោះគ្រូឡេង ថ្នាក់ទី២គ្រូគីម ថ្នាក់ទី៣គ្រូសយ ដល់ថ្នាក់ទី៤គ្រូម៉ោពីតំបន់ ។

សេង៍គា ៖ មានចាំថាតំបន់ណាទេមីងកាលហ្នឹង?

ឈ្មួន ៖ តំបន់ពាយ័ព្យ គេហៅតំបន់២កាលហ្នឹង ។

សេង៍គា ៖ តាបន់ពាយ័ព្យ តំបន់២?

ឈ្មួន ៖ ចាំ!

សេង៍គា ៖ ពាយ័ព្យហ្នឹងខាងណា?

ឈ្មួន ៖ ខាងពោធិ៍សាត់ ។

សេង៍គា ៖ បាទ!អញ្ចឹងមីងរស់នៅហ្នឹងរហូតដល់ឆ្នាំ៧៤មីង?

ឈ្មួន ៖ ចាំ!ឆ្នាំ ៧៤ម្ដាយខ្ញុំស្លាប់ ។

សេង៍គា ៖ ស្លាប់ដោយសារអីគេមីង?

ឈ្មួន ៖ ដោយសារជំងឺ ។

សេង៍គា ៖ ដល់ពេលក្រោយម៉ោមីងរស់នៅជាមួយឪពុកមារមីង?

ឈ្មួន ៖ ចាំ!

សេង៍គា ៖ ឪពុកមារមីងឈ្មោះអីដែរមីង?

ឈ្មួន ៖ ឪពុកមារខ្ញុំឈ្មោះ ចយ ។

សេងគា ៖ ឈ្មោះ ចយ?

ឈួន ៖ ចា៎!

សេងគា ៖ ឈ្មោះ ចយ ហើយមីងរស់នៅជាមួយគាត់បានប៉ុន្មានឆ្នាំដែរ បានប៉ុន្មានខែ?

ឈួន ៖ បាន៣-៤ខែ អញ្ចឹងខ្ញុំក៏ចូលម៉ោភូមិភាគពិសេស ។

សេងគា ៖ បាទ!ភូមិភាគពិសេស មិនមែនភស្តុភាពិសេសទេ?

ឈួន ៖ មិនមែនទេភូមិភាគពិសេស ។

សេងគា ៖ កាលហ្នឹងប្រធានភូមិភាគពិសេសឈ្មោះអីគេមីង?

ឈួន ៖ ឈ្មោះ អ៊ុំឡុង ។

សេងគា ៖ ឈ្មោះ ឡុង អនុឈ្មោះខុន?

ឈួន ៖ ចា៎!

សេងគា ៖ បាទ!ហើយក៏អនុញ្ញាតឲ្យមីងនៅក្នុងហ្នឹងទៅ នៅក្នុងភូមិភាគពិសេសហ្នឹង?

ឈួន ៖ ចា៎!

សេងគា ៖ នៅក្នុងកងភូមិភាគពិសេសហ្នឹងគេឲ្យមីងធ្វើអីខ្លះទៅមីង?

ឈួន ៖ គេឲ្យដើរទិញស្រូវទិញអីតាមភូមិភាគ តាមតំបន់ ឲ្យទិញស្រូវដឹកយកទៅខាងភូមិភាគពិសេសនោះ ដូចថាយើងនៅប្រចាំភូមិភាគពាយ័ព្យអញ្ចឹងគេឲ្យទិញស្រូវនៅហ្នឹងអញ្ចឹងគេដឹកទៅខាងភូមិភាគពិសេស ភូមិភាគពិសេសនៅប្រចាំខាងភូមិភាគបញ្ចឹមនោះ ខាងគេហៅ ទៅខាងកំពង់ឆ្នាំងអីហ្នឹង ។

សេងគា ៖ បាទ!ហើយបន្ទាប់មកទៀតមីង?

ឈួន ៖ បន្ទាប់មកទៀតក៏ចូលដល់ ៧៩ខែ៨ខែ៩ហ្នឹងក៏យើងចេញគឺយើងជ័យជំនះសង្គ្រាម លន់ណុលហ្នឹងក៏គេឲ្យខ្ញុំទៅនៅភ្នំពេញ តែទៅនៅបានតែ២-៣ថ្ងៃទេគេបញ្ជូនទៅស៊ឹង ត្រែង ។

សេងគា ៖ នៅភ្នំពេញគេឲ្យនៅម្តុំណាមីង?

ឈួន ៖ នៅទួលគោក ។

សេងគា ៖ បន្ទាប់មៅគេបញ្ជូនទៅស្ទឹងត្រែង?

ឈួន ៖ ទៅស្ទឹងត្រែង តែឡប់ម៉ៅវិញក៏នៅទួលគោកដដែល ។

សេងគា ៖ អ្នកណាគេ អ្នកបញ្ជូនមីងឲ្យទៅ ពូឡុងនោះដែរ?

ឈួន ៖ ចាំ!គេអ្នកបញ្ជូនហ្នឹង ពួឡូងហ្នឹងគ្រាន់តែអ្នកប្រធានមន្ទីរទេ គ្រាន់តែបញ្ជូនយើងទៅនៅមន្ទីរថ្មីកស្តុភាហ្នឹង តែដល់អញ្ចឹងទៅដល់នោះ មានពួ ប៉ុន ហ្នឹងអ្នកបញ្ជូនទៅនៅខាងឡូទៅប្រចាំការទទួល ។

សេងគា ៖ កាលហ្នឹងពីអ្នកពោធិ៍សាត់ទៅច្រើនគ្នាទេ កាលហ្នឹង?

ឈួន ៖ ទៅគ្នាច្រើន ៣-៤នាក់ដែរ តែខ្ញុំភ្លេចអស់ហើយ កាលហ្នឹងទៅនៅស្ទឹងត្រែងហ្នឹងដើម្បីទៅទទួល នៅចាំទទួលអង្ករគេដឹកតាមកាណូតតាមអីយើងលើកដាក់ឃ្លាំងហ្នឹងដើម្បីដឹកទៅខាង ។

សេងគា ៖ ស្ទឹងត្រែងនៅភូមិណាដែលមីង?

ឈួន ៖ នៅផ្សារស្ទឹងត្រែង នៅក្រុងស្ទឹងត្រែងហ្នឹងម៉ង ។

សេងគា ៖ កាលហ្នឹងជិះអីទៅ?

ឈួន ៖ ជិះឡានទៅ ។

សេងគា ៖ កាលហ្នឹងជិះឡានប៉ុន្មានថ្ងៃទៅដល់ស្ទឹងត្រែង?

ឈួន ៖ ម៉ោពីភ្នំពេញជិះកាណូតម៉ោ ជិះកាណូតកប៉ាល់ម៉ោ ម៉ោដល់ក្រចេះបានយើងជិះឡានម៉ោស្ទឹងត្រែង ។

សេងគា ៖ អញ្ចឹងទៅរយៈពេលប៉ុន្មានថ្ងៃដែរ ទៅហ្នឹង?

ឈួន ៖ ២-៣ខែដែរ ដល់ខែ២ ៧៦នោះបានខ្ញុំត្រឡប់ម៉ោវិញ ។

សេងគា ៖ អ្ហ៎!អញ្ចឹងដល់ពេលមីងត្រឡប់ម៉ោភ្នំពេញវិញ មានបញ្ហាពីណាម៉ោ នៅនោះនៅស្ទឹងត្រែងហ្នឹងអ្នកណាអ្នកកាន់កាប់មីង ប្រធានគេ?

ឈួន ៖ ប្រធានគេឈ្មោះ ធីម ហ្នឹង ។

សេងគា ៖ តា ធីម ប្រធាននៅស្ទឹងត្រែងនេះ?

ឈួន ៖ ចាំ!ដល់ពេលអញ្ចឹង លើកដាក់អង្ករហ្នឹងដើម្បីយើងបញ្ជូនឲ្យទ័ពនៅខាងរតនៈគិរី មណ្ឌលគិរីប៉ុនទីស្នាក់ការភស្តុភាអង្ករចែកចាយនៅស្ទឹងត្រែងហ្នឹងឯង ។

សេងគា ៖ ហើយនៅហ្នឹងបាន២-៣ខែមីង?

ឈួន ៖ ចាំ!នៅរហូតដល់ខែ២ ៧៦ បានយើងចេញពីហ្នឹងត្រឡប់ម៉ោវិញ ។

សេងគា ៖ ខែ២ ៧៦?

ឈួន ៖ ម៉ោនៅភ្នំពេញវិញ ។

សេងគា ៖ បើម៉ោនៅភ្នំពេញវិញ ម៉ោដល់ក្រចេះជិះកាណូតម៉ោងដដែល?

ឈួន ៖ ចាំ!តែឡប់ម៉ោវិញអត់ជិះកាណូតទេ ឡប់ម៉ោវិញជិះឡាន ។

សេងគា ៖ ជិះឡានរហូត?

ឈួន ៖ ចាំ!

សេងគា ៖ ចុះនៅឆ្នាំ៧៦ កំឡុងពេលដែលមីងនៅភ្នំពេញហ្នឹង មីងអាចរៀបរាប់ប្រាប់កន្លែងហ្នឹងបន្តិចបានមីង?

ឈួន ៖ ៧៦ម៉ោនៅភ្នំពេញក៏ខ្ញុំរស់នៅក្នុងមន្ទីរក២០ នៅមន្ទីរ២០ហ្នឹងនៅខាងចែកចាយរបស់ភស្តុភាដែរ ។

សេងគា ៖ អនុប្រធានឈ្មោះអីខ្លះមីង?

ឈួន ៖ ឈ្មោះ បងប៉ុងហ្នឹង ឈ្មោះពូហាក់ មាន៣នាក់មានគាសៅមួយទៀត ។

សេងគា ៖ ឈ្មោះ ពូសៅមួយទៀត?

ឈួន ៖ ចាំ!ហ្នឹងហើយគាត់កាន់ប្រធានខាងភស្តុភាហ្នឹង ។

សេងគា ៖ ពូ ប៉ុងហ្នឹងមីងថាឥឡូវគាត់រស់នៅកោះកុង?

ឈួន ៖ ឥឡូវគាត់រស់នៅកោះកុង តែមិនដឹងគាត់ធ្វើអីទេ?

សេងគា ៖ ចុះពូហាក់ ជាមួយនិងពូសៅគាត់ទៅណាហើយមានដឹងទេ?

ឈួន ៖ ហ្នឹងបែកគ្នាយូរហើយ មិនដឹងម៉េចទេ ។

សេងគា ៖ ហើយម៉ោនៅមន្ទីរទាំងអស់មានគ្នាប្រហែលជាប៉ុន្មានរយនាក់ទៅ?

ឈួន ៖ ៣-៤កងតូចដែរ តែអត់ដឹងកម្លាំងអត់ដឹងចំនួនទេ អត់ដឹងប៉ុន្មានផង នៅឃ្លាំងហ្នឹង ។

សេងគា ៖ ៣-៤កងតូចដែរ អញ្ចឹងមានគ្នាប្រហែលជា១០០នាក់ដែរមីង?

ឈួន ៖ ចាំ!ប្រហែលហ្នឹងមិនដឹង ស្មានទៅប៉ុនហ្នឹង ។

សេងគា ៖ បាទ!ចុះបន្ទាប់មកទៀតមីង?

ឈួន ៖ បន្ទាប់មកទៀតអ៊ើ ។

សេងគា ៖ នៅត្រង់ហ្នឹងបានប៉ុន្មានខែ?

ឈួន ៖ ខ្ញុំនៅពី៧៦ម៉ោដល់៧៧ខ្ញុំនៅបាន១ឆ្នាំជាងគេឲ្យដូរពីមន្ទីរក២០ម៉ោនៅសព្វពិសិដ្ឋ ។

សេងគា ៖ ឡុង ហ្នឹងអ្នកឲ្យដូរ?

ឈួន ៖ អត់ទេ!មិនមែនពូឡុងទេ ប៉ុង ។

សេងគា ៖ ប៉ុង?

ឈួន ៖ ចា៎!ប៉ុន ហ្នឹងគាត់អ្នកជ្រើសរើសដូចថា កម្លាំងខាងសព្វពីសិដ្ឋហ្នឹងគេខ្វះកម្លាំងគេសុំឲ្យខាងក២០ជំនួយខ្លះ អញ្ចឹងគេសុំកម្លាំងយើងគេជ្រើសរើសប្រវត្តិរូបទៀត ។

សេងគា ៖ បាទ!១២នាក់ ។

ឈួន ៖ ចា៎!យកទៅៗសព្វពិសិដ្ឋៗហ្នឹងនៅខាងឃ្លាំងទ្រព្យ ។

សេងគា ៖ បាទ!តែនៅទួលគោកដដែលមីង?

ឈួន ៖ នៅទួលគោក ។

សេងគា ៖ នៅជិតអង់តែនហ្នឹងមីង?

ឈួន ៖ នៅម៉ាជួរផ្ទះគេកាច់នេះហ្នឹង ។

សេងគា ៖ អ្ហូ!បាទផ្ទះគេធំៗហ្នឹង?

ឈួន ៖ ចា៎!

សេងគា ៖ ផ្ទះធំៗហ្នឹងគេយកទៅដាក់ឃ្លាំងទ្រព្យទាំងអស់មីង?

ឈួន ៖ ចា៎!នៅខាងសព្វពិសិដ្ឋ នៅខាងនោះគេដាក់ឃ្លាំងទ្រព្យ នៅផ្សារទួលគោកនោះ ។

សេងគា ៖ បាទ!អញ្ចឹងមីងទៅនៅជិតផ្សារទួលគោកកាលហ្នឹង?

ឈួន ៖ ចា៎!ទៅនៅសព្វសិដ្ឋជិតផ្សារទួលគោក ។

សេងគា ៖ ឈ្មោះអីគេ?

ឈួន ៖ មន្ទីរសរប៉៉េតសិដ្ឋ ខាងលើកដាក់ទ្រព្យដើម្បីយកទៅឲ្យកងទ័ពហ្នឹង ។

សេងគា ៖ នៅក្នុងមន្ទីរហ្នឹងអ្នកណាគេប្រធានមិញ?

ឈួន ៖ អ្នកប្រធានបងកាន ។

សេងគា ៖ គាកានមីង?

ឈួន ៖ ចា៎!

សេងគា ៖ ឥឡូវគាត់រស់នៅប៉ៃលិនទេ គាត់ចៅហ្វាយក្រុងមីង?

ឈួន ៖ ចា៎!ប៉ុអតីតកាលមុនមិនដឹងគាត់នៅណាមិនដឹងទេ តែជំនាន់នេះគាត់មកក្តាប់យើងនៅហ្នឹង ។

សេងគា ៖ អ្ហូ!បាទអញ្ចឹងរត់គាត់តាមផ្លូវរដាតិដែរ?

ឈួន ៖ អត់បានរត់តាមហ្នឹងទេ ។

សេងគា ៖ បាទ!ចុះបន្ទាប់មកទៀតចេញពីហ្នឹងម៉ោមីង?

ឈួន ៖ ចេញពីសព្វសិដ្ឋហ្នឹងម៉ោយើងរត់ចេញ ។

សេងគា ៖ មីងនៅសព្វសិដ្ឋរហ់ដល់ណា?

ឈួន ៖ រហូតដល់៧៩ ។

សេងគា ៖ កាលហ្នឹងគេឲ្យធ្វើអីខ្លះនៅសព្វសិដ្ឋហ្នឹង?

ឈួន ៖ នៅលើកគ្រាប់ លីគ្រាប់ដាក់ឡានដឹកម៉ោសមរភូមិ ម៉ោខាងស្វាយរៀងហ្នឹងទៅលើកគ្រាប់ដាក់ឡានគេដឹកម៉ោខាង ឡានគេដឹកម៉ោ ។

សេងគា ៖ អញ្ចឹងពេលដែលមីងម៉ោដល់សព្វសិដ្ឋមីងមានប្រធានតែឈ្មោះ កាន មួយទេចុះអនុប្រធានមានចាំទេមីង?

ឈួន ៖ អនុប្រធានមិនដឹងណាណីខ្លះទេ អត់ចាំទេ ព្រោះផ្លាស់ប្តូរច្រើន ខ្មោចពូធឹម ហ្នឹងក៏គាត់ធ្លាប់នៅសព្វសិដ្ឋដែរ ។

សេងគា ៖ គាត់ធ្លាប់នៅជាមួយគ្នា ប៉ុន្តែគាត់ដូរម៉ោកន្លែងវិញ?

ឈួន ៖ ចាំ!

សេងគា ៖ បាទ!នៅពេលដែលមីងនៅហ្នឹង មីងជាធ្លប់បានទៅមើលកុនដែរមីង?

ឈួន ៖ ចាំ!

សេងគា ៖ ទៅមើលកុនហ្នឹងមួយឆ្នាំមីងទៅមើលបានប៉ុន្មានដងដែរមីង កុនហ្នឹងគេបញ្ចាំងពីកុនចិន ទេ?

ឈួន ៖ កុនចិន ។

សេងគា ៖ ខ្មែរយើងអត់មានទេ?

ឈួន ៖ ខ្មែរមានដែរ ។

សេងគា ៖ ខ្មែរហ្នឹងមានបញ្ចាំងពីរឿងអីទៅមីង?

ឈួន ៖ ភ្លេចអស់ហើយមិនដឹងពីរឿងអីទេ ។

សេងគា ៖ ចុះរឿងចិនគេបញ្ចាំងម៉ោមានរូបភាពអីខ្លះមីង?

ឈួន ៖ រឿងចិនជំនាន់ហ្នឹងមានរឿងក្រឡេយ៉ង់សេ មានរឿងកុមារស្អីគេមិញទេ ភ្លេចអស់ហើយ ។

សេងគា ៖ ហើយគេលេងហ្នឹងដើម្បីអីគេ គេលេងហ្នឹង?

ឈួន ៖ គេលេងឲ្យយើងមើល ឲ្យយើងមើលទៅរឿងចិនហ្នឹងវាមានសង្គ្រាមចេះចុះ ។

សេងគា ៖ អ្ហូ!អញ្ចឹង គេបញ្ចាំងនៅស្តាតមីង?

ឈួន ៖ នៅស្តាត ។

សេងគា ៖ ហើយមីងបានឃើញប៉ុល ពត បានឃើញ?

ឈួន ៖ អត់ដែលបានឃើញទេ ដូចខ្ញុំថាអញ្ចឹង ប៉ុល ពត បានឃើញនៅក្នុងកុន តែបើតា អៀង សារី តាខៀវ សំផនអីធ្លាប់ឃើញម្ដងយាម ។

សេងគា ៖ ឃើញនៅពេលដែលគាត់មោប្រជុំហ្នឹង?

ឈួន ៖ ចា៎!

សេងគា ៖ បាទ!នៅពេលឆ្នាំ៧៩ ពេលដែលវៀតណាមកំពុងតែវាយកទីក្រុងភ្នំពេញមីងបានរត់ចេញម៉ោមុន?

ឈួន ៖ ចា៎!រត់ចេញម៉ោ ។

សេងគា ៖ តាមឡានទ័ពហ្នឹងមីង?

ឈួន ៖ តាមឡានទ័ព ដឹកគ្រាប់ម៉ោ ។

សេងគា ៖ ហើយរត់ចេញមុនដំបូងដល់កន្លែងណាមីង?

ឈួន ៖ ដូចខ្ញុំប្រាប់អញ្ចឹង រត់ចេញម៉ោដឹកគ្រាប់ម៉ោ ម៉ោដាក់នៅភ្នំជ្រីវឱរ៉ាល់ហ្នឹង ។

សេងគា ៖ អ្ហូ!ហ្នឹងគេហៅភ្នំជ្រីវឱរ៉ាល់មីង?

ឈួន ៖ ចា៎!

សេងគា ៖ បាទ!ហើយបន្ទាប់មកទៀតមីង?

ឈួន ៖ បន្ទាប់មកទៀត ។

សេងគា ៖ នៅហ្នឹងបានប្រហែលជាមួយខែមីង?

ឈួន ៖ ២-៣ខែដែរភ្លេចអស់ហើយ ដល់ពេលអញ្ចឹងក៏គេឲ្យយើងដកចេញ ។

សេងគា ៖ គេឲ្យដកចេញ?

ឈួន ៖ យើងដើរម៉ោគេឲ្យដកចេញ ដកម៉ោយើងដើរ ។

សេងគា ៖ នៅហ្នឹងគេឲ្យយើងធ្វើអីមីង ទៅយាមគ្រាប់មីង?

ឈួន ៖ ទៅចាំគ្រាប់ គេដឹកគ្រាប់យកទៅដាក់ភ្នំហ្នឹងគេឲ្យយើងចាំ ។

សេងគា ៖ ហើយប្រធាននៅហ្នឹងឈ្មោះអីទៅ នៅកាន់ទ័ពកន្លែងភ្នំឱរ៉ាល់ហ្នឹង?

ឈួន ៖ កាលហ្នឹងគេឲ្យពួកខ្ញុំនៅចាំហ្នឹងអត់មានប្រធានមានអីទេ ។

សេងគា ៖ កាលហ្នឹងប្រចាំមានគ្នាប៉ុន្មាននាក់?

ឈួន ៖ ប្រចាំគ្នា៧-៨នាក់ ។

សេងគា ៖ ៧-៨នាក់ មានចាំឈ្មោះខ្លះទេមីង?

ឈួន ៖ ភ្លេចអស់ហើយ ចាំបានតែ២នាក់ ។

សេងគា ៖ អ្នកណាគេខ្លះ?

ឈួន ៖ ឈ្មោះ ធឿន ហ្នឹងមួយស្រី ។

សេងគា ៖ ហើយអ្នកណាមួយទៀត?

ឈួន ៖ ហើយបែកគ្នាអស់ហើយ ។

សេងគា ៖ ដល់ពេលហ្នឹងហើយ បាន២-៣ខែគេដកឲ្យមីងម៉ោខាងពាយ័ព្យវិញ?

ឈួន ៖ ចា៎!ម៉ោពាយ័ព្យវិញ ។

សេងគា ៖ ម៉េចបានគេដកឲ្យម៉ោ?

ឈួន ៖ គេថាឈួនចូលអុកឡុកទៅ គេឲ្យយើងដកចេញ ។

សេងគា ៖ ហើយមានយកគ្រាប់ម៉ោទេកាលហ្នឹង?

ឈួន ៖ ទុកគ្រាប់នៅហ្នឹងមិនដឹងខាងគេ អុស៎!គ្រាប់ហ្នឹងគេប្រគល់ឲ្យខាងតាម៉ុក ។

សេងគា ៖ មានបានទៅទទួលតាម៉ុកទេកាលហ្នឹង?

ឈួន ៖ ឃើញដែលតាស៎ ។

សេងគា ៖ អ្ហ៊ូ!តាម៉ុកមកជួបកងទ័ព?

ឈួន ៖ អត់ទទួលផ្ទាល់ទេ ខាងដូចថាមានមេមានកើយគេទាក់ទងគ្នាហ្នឹង គេប្រាប់ថាឥឡូវគ្រាប់
ហ្នឹងគេប្រគល់ឲ្យខាងតាម៉ុកហើយ គេឲ្យយើងដកចេញ ។

សេងគា ៖ អ្ហ៊ូ!អញ្ចឹង ហើយខាងតាម៉ុកក៏ម៉ោទទួលទៅ?

ឈួន ៖ ទទួលទៅហើយឡានគេ ។

សេងគា ៖ ហើយមីងធ្លាប់ឃើញតាម៉ុកជិះឡានអីម៉ោដែរ?

ឈួន ៖ ចា៎!ឃើញ ។

សេងគា ៖ ជិះឡានអីទៅមីងកាលហ្នឹង?

ឈួន ៖ ជិះឡានអាកាម៉ង់កាចិនហ្នឹង ។

សេងគា ៖ កាម៉ង់កាចិនហ្នឹង?

ឈួន ៖ ចា៎!

សេងគា ៖ ដល់ពេលអញ្ចឹងទៅមីងក៏ដើរម៉ោរហូត ដើរម៉ោពីឱរ៉ាល់ហ្នឹងប៉ុន្មានថ្ងៃបានម៉ោដល់ កន្លែង?

ឈួន ៖ ឡើងច្រើនថ្ងៃដែលហ្នឹង ឡើងបាន៨-១០ថ្ងៃយូរដែលហ្នឹង ។

សេងគា ៖ កន្លែងហ្នឹងគេហៅស៊ឹងឆ្អិន?

ឈ្មួន ៖ ស៊ីងឆ្អិន ម៉ោពីជ្រីវហ្នឹងម៉ោធ្លាក់មកនៅ ស៊ីងឆ្អិនហ្នឹងក៏កន្ធែងទ្រព្យដែរ ។

សេងគា ៖ ម៉ោនៅស៊ីងឆ្អិនហ្នឹងបានប្រហែលប៉ុន្មានខែ?

ឈ្មួន ៖ ៣-៤ថ្ងៃ ក៏គេឲ្យចេញម៉ោទៀតគេថាឃ្មួនចូលម៉ោ ។

សេងគា ៖ ៣-៤ថ្ងៃក៏ម៉ោដល់កន្ធែងឃុំតាឡូវិញមីង?

ឈ្មួន ៖ ចា៎!

សេងគា ៖ ម៉ោដល់គេឲ្យធ្វើអីទៀតមីង?

ឈ្មួន ៖ ម៉ោដល់ហ្នឹងគេឲ្យយើងធ្វើអីទេ កិនស្រូវកិនអង្ករហូប ។

សេងគា ៖ យកទៅជួយទ័ព?

ឈ្មួន ៖ ចា៎!

សេងគា ៖ យកអីកិនកាលហ្នឹង?

ឈ្មួន ៖ ស្រូវនៅតាមសហករណ៍គេយកមកឲ្យយើងកិន ។

សេងគា ៖ កាលហ្នឹងកិនដៃទទេមីង?

ឈ្មួន ៖ កិនដៃជាន់ គេយកយើងឲ្យទៅនៅក្នុងក្រុមសហករណ៍គេ ឲ្យធ្វើស្រូវអង្ករសហករណ៍គេហ្នឹង ។

សេងគា ៖ ហើយនៅពេលដែលមីងកិនស្រូវហ្នឹងបានរយៈពេលប៉ុន្មានខែប៉ុន្មានថ្ងៃដែរ?

ឈ្មួន ៖ ប្រហែលជា១ខែ ។

សេងគា ៖ ប្រហែលជា១ខែបានមីងឡើងទៅភ្នំក្រវាញវិញ?

ឈ្មួន ៖ ចា៎!រត់ឡើងលើភ្នំហើយ បានធ្លាក់ទៅដីថៃ ធ្លាក់ទៅខាងជំរុំខ្ញងយៃ ។

សេងគា ៖ ម៉េចបានមីងរត់ម៉ោក្រវាញ ធ្លាក់ម៉ោខាងដីថៃវិញ?

ឈ្មួន ៖ វាតាមគ្នាទៅ ។

សេងគា ៖ ខ្លាចទាហានវៀតណាម?

ឈ្មួន ៖ ចា៎!

សេងគា ៖ គេទៅតាមគ្នាយើងទៅដែរទៅ?

ឈ្មួន ៖ ចា៎!គេទៅគ្នាច្រើនយើងរត់តាមគេទៅ ។

សេងគា ៖ កាលហ្នឹងរត់គ្នាច្រើនមីង?

ឈ្មួន ៖ គ្នាច្រើន ។

សេងគា ៖ ឡើងភ្នំអស់រយៈពេលប៉ុន្មានថ្ងៃប៉ុន្មានខែទៅ?

ឈួន : ប្រហែល១ខែដាងដែរហ្នឹង ដាច់បាយដាច់ទឹកងាប់មិនចេះអស់គិតទេកាលហ្នឹង ។

សេងគា : អ៊ូ!ងាប់ច្រើនមីង?

ឈួន : ចា៎!

សេងគា : ហើយមីងអត់អីទេ អត់ឈឺអត់អីទេ?

ឈួន : ខ្ញុំវាសំណាងដែរ ប៉ិះងាប់គេដែរ ។

សេងគា : ហើយម៉ោនៅដីថ្ងៃហ្នឹង នៅកន្លែងណាដែរ?

ឈួន : ខ្លងយ៉ៃ ។

សេងគា : នៅជំរុំខ្លងយ៉ៃ?

ឈួន : ចា៎!

សេងគា : ហើយនៅហ្នឹងបានប៉ុន្មានថ្ងៃដែរ?

ឈួន : នៅម៉ាអាទិត្យបានចេញវិញៗ ក៏ចេញម៉ោចេញម៉ោក៏ជួបតាធឹម គ្នាធ្លាប់ស្គាល់គាត់ហ្នឹងសុំគាត់ម៉ោនៅជាមួយ ។

សេងគា : ដែលធ្លាប់ប្រធានភស្តុភាពីមុនហ្នឹង?

ឈួន : ចា៎!ធ្លាប់នៅជាមួយគាត់ ។

សេងគា : ហើយតាភឹមស្នាក់នៅដីថៃរហូតដែលមីង?

ឈួន : ចា៎!នៅដីថៃរហូតនាំ ។

សេងគា : នាំទ័ពទៅច្រើនទេកាលហ្នឹងមីង?

ឈួន : យើងម៉ោទៅដាក់ៗ បានចេញខាងនេះវិញ ។

សេងគា : តាធឹម ហ្នឹងគាត់ស្លាប់នៅឆ្នាំណា?

ឈួន : តាភឹម ហ្នឹងគាត់អត់កាន់ទ័ពទេ គាត់នៅខាងភស្តុភាររហូត ម៉ោនៅដីថៃហ្នឹងក៏ទទួលខាងពួកខ្ញុំម៉ោនៅឃ្លាំងដែរ នៅឃ្លាំងអង្ករឃ្លាំងអីហ្នឹង ។

សេងគា : ឃ្លាំងដឹកអង្ករ?

ឈួន : ចា៎!គេដឹកអង្ករម៉ោពីថៃម៉ោយើងទៅទទួលពីនេះទៅ ហើយចែកចាយឲ្យតាមកងពលតាមអីអញ្ចឹងទៅ ។

សេងគា : ទាល់ឆ្នាំ៨៣បាន សុន សេន ហៅឲ្យម៉ោវិញក៏ម៉ោវិញទៅ?

ឈួន : ចា៎!

សេងគា : ចុះមីងដឹងថាតាធឹម ហ្នឹងគាត់ស្លាប់តាំងពីពេលណាទៅ?

ឈួន ៖ ស្លាប់គាត់ផុះពេលផុះមីន ។

សេងគា ៖ អ៊ូ!គាត់ជាន់មីនផុះ?

ឈួន ៖ ចាំ!

សេងគា ៖ នៅកន្លែងណាមីន?

ឈួន ៖ ជាន់មីនផុះនៅយើង៣០នេះ តែគាត់សពគាត់នៅកន្លែងអូរអន្ទក់នេះ ។

សេងគា ៖ អូរអន្ទក់ថៃទេមីង?

ឈួន ៖ ដីខ្មែរយើង ។

សេងគា ៖ អូរអន្ទក់ហ្នឹងនៅភូមិអីគេមីង?

ឈួន ៖ នៅភូមិអូរអន្ទក់ហ្នឹងម៉ង ឃុំតាសាន់ ស្រុកកំរៀង ។

សេងគា ៖ ផុះគាត់នៅត្រង់នេះទេ តែស្លាប់ៗនៅខាងនោះ?

ឈួន ៖ ផុះគាត់នៅកន្លែងហ្នឹង តែគេសែងដឹកគាត់យកម៉ោនេះ ។

សេងគា ៖ អ៊ូ!ផុះគាត់នៅហ្នឹងមីង?

ឈួន ៖ ចាំ!ផុះជិតនាន់ហ្នឹង យើងនៅវ៉ៃគ្នានៅឡើយទេ គាត់ទៅប្រចាំការនៅ៣០ កាលហ្នឹងនៅព្រៃ ។

សេងគា ៖ ៣០ហ្នឹងកាលហ្នឹងគេហៅអីគេកន្លែងហ្នឹង?

ឈួន ៖ ភូមិ៣០ហ្នឹងហើយ ។

សេងគា ៖ ភូមិ៣០?

ឈួន ៖ ចាំ!គាត់ទៅប្រចាំការនៅហ្នឹង កាលហ្នឹងព្រៃ ហើយពួកខ្ញុំកាលហ្នឹងនៅនារីកងដឹក ជញ្ជូន ។

សេងគា ៖ អ៊ូ!កាលហ្នឹងមីងទៅដឹកជញ្ជូនឲ្យគាត់ដែរ?

ឈួន ៖ ចាំ!ដឹកជញ្ជូនឲ្យពួកទ័ពទៅមុខ ទូលគ្រាប់ទូលអីហ្នឹង យើងអត់មានឡានមានអីដឹកទេ កាលហ្នឹង ។

សេងគា ៖ ឆ្នាំប៉ុន្មានកាលគាត់ស្លាប់ហ្នឹង ឆ្នាំ៨០ប៉ុន្មានឬ៩០ហើយ?

ឈួន ៖ ៨០ប៉ុន្មានទេ ។

សេងគា ៖ រៀបការមីងហើយនៅ?

ឈួន ៖ ចាំ!រៀបការខ្ញុំហើយ ។

សេងគា ៖ មីងរៀបការមិញនៅឆ្នាំ៨៩?

ឈួន ៖ ចាំ!៨៩ អាចគាត់ស្លាប់នៅឆ្នាំ៩០ហើយ ។

សេងគា ៖ ដល់ឆ្នាំ១៩៨៤ តាភីម គាត់បែងចែកដីឲ្យ?

ឈួន ៖ ចាំ!

សេងគា ៖ ម្នាក់បានប៉ុន្មានមីង?

ឈួន ៖ ម្នាក់បានក្បាល៤០ ហើយបណ្ដោយកាប់បានប៉ុណ្ណាយកប៉ុនហ្នឹង ។

សេងគា ៖ បាទ!ដល់ហើយនៅពេលដែលរស់នៅដីថៃហ្នឹង មីងថារស់នៅបាន៣-៤ឆ្នាំដែរមីង?

ឈួន ៖ ចាំ!

សេងគា ៖ តាមជាយដែនថៃ តាមព្រៃហ្នឹង?

ឈួន ៖ ចាំ!តាមជាយដែនតាមព្រៃ ។

សេងគា ៖ ហើយពេលដែលចូលមកដល់ដីថៃដំបូងមីងនៅ អុស៎!ម៉ោដល់ដីខ្មែរដំបូងមីងនៅភូមិអី?

ឈួន ៖ នៅភូមិអូរ គេហៅភូមិភ្លើងឆេះ ។

សេងគា ៖ គេហៅភូមិភ្លើងឆេះពីមុន?

ឈួន ៖ ចាំ!

សេងគា ៖ ឃុំ?ឃុំពេជ្រចិន្ដាដែរ?

ឈួន ៖ ចាំ!តែឥឡូវកើតភូមិ កើតអីទៅគេដាក់ភូមិពេជ្រចិន្ដា ភូមិអូរ ។

សេងគា ៖ បាទ!ភូមិពេជ្រចិន្ដា ភូមិអូរ តែដល់ពេលតាភីម គាត់ចែកដីឲ្យនៅនេះទៅក៏ម៉ោនៅហ្នឹងទៅ?

ឈួន ៖ ចាំ!នៅម៉ាគ្រួសារៗ ។

សេងគា ៖ បាទ!អញ្ចឹងមីងមានអីចង់បន្ថែមទៀតទេ?

ឈួន ៖ អត់មានទេ ។

សេងគា ៖ អត់មានទេ! អញ្ចឹងខ្ញុំអរគុណមីងច្រើន ដែលមករំខានពេល អញ្ចឹងអរគុណមីងជំរាបលាមីង ។

ឈួន ៖ ចាំ!

ចប់